**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

# សារលិខិតរំលែកទុក្ខ

# ជូនចំពោះលោកជំទាវ ជួន គីម និងក្រុមគ្រួសារ

*លោកជំទាវជាទីគោរពរាប់អាន!*

ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋក្នុងខេត្តកំពង់ធំ មានក្តីរន្ធត់ក្តុកក្តួលឥតឧបមា ចំពោះមរណភាពរបស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលជាស្វាមីរបស់លោកជំទាវ បានទទួលមរណភាពកាលពីថ្ងៃសៅរ៍ ៨កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ០៦:៤៥ នាទីព្រឹក ក្នុងជន្មាយុ ៧១ឆ្នាំ ដោយរោគាពាធ ។

ការទទួលមរណភាពរបស់ **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ឯម សំអាន** គឺជាការបាត់បង់នូវស្វាមី ឪពុក ឪពុកក្មេក និងជីតា ជាទីគោរពស្រឡាញ់ និងប្រកបដោយព្រហ្មវិហារធម៌មួយរូបចំពោះបុត្រធីតា និងចៅៗ ហើយក៏ជាការបាត់បង់នូវអតីតយុទ្ធជនដ៏ឆ្នើមមួយរូប ដែលធ្លាប់បានចូលរួមចំណែកយ៉ាងសកម្មក្នុងបុព្វហេតុកសាង ស្តារ និងអភិវឌ្ឍសង្គម នាំមកនូវសុខសន្តិភាពជូនប្រជាពលរដ្ឋ និងមាតុភូមិកម្ពុជា ។ ទន្ទឹមនេះ **ឯកឧត្តម** ក៏ជានាយនគរបាលជាតិជាន់ខ្ពស់មួយរូប ដែលបានបំពេញការងារយ៉ាងស្មោះស្ម័គ្រ និងមានស្នាដៃជាច្រើនក្នុងការងារថែរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈជូនសង្គមជាតិ ព្រមទាំងទទួលបាននូវការគោរពស្រឡាញ់រាប់អានពីគ្រប់មជ្ឈដ្ឋាន ជាពិសេស នាយនគរបាល និងពលនគរបាលជាតិនៃក្រសួងមហាផ្ទៃគ្រប់លំដាប់ថ្នាក់ ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុតនេះជាមួយ **លោកជំទាវ** និងក្រុមគ្រួសារ និងសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ឯម សំអាន** បានសោយសុខក្នុងសុគតិភពជានិច្ចនិរន្តរ៍តរៀងទៅ ។

សូម **លោកជំទាវ** ព្រមទាំងក្រុមគ្រួសារ មេត្តាទទួលនូវសេចក្តីគោរពរាប់អានដ៏ជ្រាលជ្រៅបំផុតអំពីយើងខ្ញុំ ។

ថ្ងៃចន្ទ១០ កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ខេត្តកំពង់ធំ ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៨

**អភិបាល**

**សុខ~លូ**